Civil society Links and Empowerment for Socially Inclusive Development in Ratanakiri



# គោលការណ៍យុទ្ធសាស្ត្រនៃខ្សែសង្វាក់តម្លៃអេកូទេសចរណ៍ ក្នុងខេត្តរតនគិរី ប្រទេសកម្ពុជា

## ILS LEDA

ការសិក្សានេះត្រូវបានចងក្រងដោយអ្នកជំនាញរបស់ ILSLEDA ក្នុងក្របខ័ណ្ឌនៃគម្រោង "CLESIDRA: ការចងបណ្តាញ និងការពង្រឹងសង្គមស៊ីវិលសម្រាប់ការអភិវឌ្ឍន៍សង្គមបែបបរិយាបន្ន ក្នុងខេត្តរតនគិរី" ដែលសហការផ្តល់មូលនិធិដោយសហភាពអឺរ៉ុប។

ខែកញ្ញា 2024

# ជំពូកទី៥ គោលការណ៍យុទ្ធសាស្ត្រសំដៅការប្រកួតប្រជែង និងការអភិវឌ្ឍន៍ខ្សែបរិយាបន្ន

## *5.1.* វិធីសាស្ត្រក្នុងការបង្កើតគោលការណ៍យុទ្ធសាស្ត្រអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃអេកូទេសចរណ៍

ការប្រើប្រាស់វិធីសាស្ត្រ រេស្កូ(RESCO) សម្រាប់ការបកស្រាយលម្អិតនៃគោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ ប្រើប្រាស់ធាតុចូលដែលដំណើរការពីការវាយតម្លៃ រេស្កូ(RESCO) (សម្ភាសន៍) ពីការវិភាគនៃភាពបន្ទាប់បន្សំ និងពីការពិគ្រោះយោបល់ជាមួយអ្នកជំនាញ និងចាត់ថ្នាក់។

ធាតុចូលទាំងអស់នេះសំដៅទៅលើសូចនាករនៃចំនុចអថេរនីមួយៗដែលឆ្លើយតបទៅនឹងកត្តារបស់វា បើទោះបីជាវាវិជ្ជមាន (ចំណុចខ្លាំង) ឬអវិជ្ជមាន (ចំណុចខ្សោយ) ដូចដែលបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម។




សកម្មភាពជាយុទ្ធសាស្ត្រ គួរតែត្រូវបានដោះស្រាយដើម្បី៖

a. រក្សាចំនុចខ្លាំងក្នុងរយៈពេលយូរ

b. ដកចេញនូវចំនុចខ្សោយព្រោះវាជាឧបសគ្គដល់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ

វិធីសាស្ត្រ រេស្កូ(RESCO) ប្រើក្បួនដោះស្រាយដ៏សាមញ្ញមួយសម្រាប់ការទាញយកសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់ "ចំនុចអថេរ" នីមួយៗដែលត្រូវគ្នានឹង "កត្តា" ផ្សេងៗគ្នា។

ក្បួនខ្នាតរបស់វាគឺបែបនេះ៖

**$Sa = f(V_{ij}, Fa_n)$**

*Sa= Strategic Actions យុទ្ធសាស្ត្រសកម្មភាព*

*$V_{ij}$= Variable "i" of the Component "j" ចំនុចអថេរ*

*$Fa_n$= Factor "n" កត្តា*

## *5.2.* ពីសក្តានុពលនិងតម្រូវការ ទៅជាសកម្មភាព

សក្តានុពលនិងតម្រូវការសំខាន់ៗដែលសំដៅលើកត្តានីមួយៗ និងអថេរដែលត្រូវគ្នា ត្រូវបានបង្ហាញនៅក្នុងជំពូកទី ៥។

ដំណើរការពីការដោះស្រាយសកម្មភាពជាយុទ្ធសាស្ត្រទៅនឹងតម្រូវការដែលបានរៀបរាប់ខាងលើបានមើលឃើញថា:

1. កំណត់សកម្មភាពនីមួយៗសម្រាប់ចំនុចអថេរនីមួយៗ
2. ចងក្រងក្រុមសកម្មភាពបំពេញបន្ថែម
3. លុបបំបាត់ភាពស្ទួន
4. រួមបញ្ចូលសកម្មភាពនីមួយៗដែលត្រូវគ្នានឹង "វិស័យយុទ្ធសាស្ត្រ"

ដូច្នោះហើយ ការវាយតម្លៃរបស់ រេស្កូ(RESCO) ក៏បានផ្តល់នូវវិស័យសកម្មភាពជាយុទ្ធសាស្ត្រយ៉ាងហោចណាស់ចំនួន ៣ដូចជា៖

a.អភិបាលកិច្ច

b.ការកសាងសមត្ថភាព

c.ប្រព័ន្ធសេវាកម្ម

*យុទ្ធសាស្ត្រនីមួយៗឆ្លើយតបទនឹងគោលដៅសំខាន់ដូចជា៖*

I. *ការបង្កើតវេទិកាសម្រាប់កិច្ចសន្ទនាសង្គម ដើម្បីពង្រឹងឱកាសការងារប្រចាំថ្ងៃសម្រាប់ប្រជាជនគោលដៅ*

II. *លើកកម្ពស់និរន្តភាពសង្គម និងបរិយាបន្ន*

III. *លើកកម្ពស់និរន្តភាពបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ*

ប្រអប់ខាងក្រោមបង្ហាញពីរបៀបដែលវិស័យយុទ្ធសាស្ត្រនីមួយៗចូលរួមចំណែកក្នុងការសម្រេចបាននូវគោលដៅ

*ដោយពិចារណាលើអាទិភាពដែលបានលេចចេញពីការវិភាគស្ថានភាពនិងសក្តានុពលនៃខ្សែសង្វាក់តម្លៃអេកូទេសចរណ៍ និងគោលដៅរបស់គម្រោង ខ្លេស៊ីដ្រា(CLESIDRA) សកម្មភាពជាយុទ្ធសាស្ត្រទាំងនេះត្រូវបានចងជាក្រុមដោយយោងទៅតាមបីកម្រិតនៃអាទិភាព:*

- *អាទិភាពលេខ ១ សកម្មភាពដែលត្រូវគ្នានឹងគោលបំណង និងសំណើនៃផែនការការងាររបស់គម្រោង :ខ្លេស៊ីដ្រា(CLESIDRA) (សូមមើលប្រអប់ទី ១) អាទិភាពខ្ពស់" ហើយក្នុងពេលជាមួយគ្នានេះត្រូវគ្នានឹង (HP)" ដែលបានចង្អុលបង្ហាញដោយក្រុម រេស្កូ(RESCO)។*

- *អាទិភាពលេខ ២) អាទិភាពខ្ពស់" សកម្មភាពដែលត្រូវគ្នានឹង :HP)" ដែលបានចង្អុលបង្ហាញដោយក្រុម រេស្កូ (RESCO) ប៉ុន្តែមិនត្រូវបានមើលឃើញយ៉ាងច្បាស់ក្នុងផែនការសកម្មភាព និងមូលនិធិជំនួយរបស់គម្រោង ខ្លេស៊ីដ្រា(CLESIDRA)។*
- *អាទិភាពលេខ ៣) អាទិភាពមធ្យម" សកម្មភាពដែលត្រូវគ្នានឹង :MP)" ដែលបានចង្អុលបង្ហាញដោយក្រុម រេស្កូ(RESCO)។*

## ប្រអប់ទី 1. ផែនការ ខ្លេស៊ីដ្រា(CLESIDRA)

**WP1 - ការបង្កើនជំនាញរបស់សង្គមស៊ីវិល (CSOs) អ្នកផលិត និងអាជ្ញាធរមូលដ្ឋាន (LAs) លើកិច្ចសន្ទនាជាមួយអ្នកពាក់ព័ន្ធ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមបែបបរិយាបន្ន**

A1.1 សិក្ខាសាលាកសាងសមត្ថភាពសម្រាប់ CSOs លើការចូលរួមយ៉ាងសកម្មក្នុងដំណើរការសម្រេចចិត្ត និងកិច្ចសន្ទនាជាមួយពាក់ព័ន្ធ។

A1.2 សិក្ខាសាលាកសាងសមត្ថភាពលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គមបែបបរិយាបន្ន ការប្រកួតប្រជែង និងនិរន្តរភាពខ្សែសង្វាក់តម្លៃ។

A1.3 សិក្ខាសាលាកសាងសមត្ថភាព និងការគាំទ្រដើម្បីលើកកម្ពស់សមត្ថភាព CSOs (អភិបាលកិច្ចផ្ទៃក្នុង ផលប៉ះពាល់ ការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ ការតស៊ូមតិ ការបង្កើត និងការគ្រប់គ្រងគម្រោង)

A.1.4 សិក្ខាសាលាកសាងសមត្ថភាព និងជំនួយបច្ចេកទេសដល់ CSOs លើបច្ចេកទេស/វិធីសាស្រ្តផលិតកម្មប្រកបដោយនិរន្តរភាព ការអភិរក្សធនធានធម្មជាតិ និងសន្តិសុខកសិករខ្នាតតូច (រួមទាំងសិទ្ធិកាន់កាប់ដីធ្លី)

**WP2** - ការបង្កើតជាវេទិកា ផ្លាសិដ(**PLASED**) ជាមួយអ្នកពាក់ព័ន្ធ

A2.1: ការផ្តល់ជំនួយបច្ចេកទេសក្នុងការរចនា និងការចាប់ផ្តើមវេទិកា ផ្លាសិដ(PLASED)

A2.2 ការចាប់ផ្តើមវេទិកា ផ្លាសិដ(PLASED) និងការអនុវត្តសកម្មភាពជាយុទ្ធសាស្រ្ត

A2.3: ការអភិវឌ្ឍ ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅស្តីពីបទពិសោធន៍ ផ្លាសិដ(PLASED)

**WP3 - ការរៀបចំអោយមានការចូលរួមពីភាគីទាំងអស់នៃយុទ្ធសាស្រ្ត (STRAT) សម្រាប់ការអភិវឌ្ឍខ្សែសង្វាក់តម្លៃបែបប្រកួតប្រជែង បរិយាបន្ន និរន្តរភាព និងភាពធន់**

**WP4 - ការបង្កើតប្រព័ន្ធសេវាកម្មដំទូលំទូលាយ** កុស្ស(COSS)

A4.1 ការគូសប្លង់ និងការវិភាគរបស់អ្នកផ្តល់សេវា/ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងខេត្តរតនគិរី

A4.2 ជំនួយបច្ចេកទសសម្រាប់រចនា កុស្ស(COSS)

A4.3 ការកសាងសមត្ថភាព និងជំនួយបច្ចេកទេសដល់ការចាប់ផ្តើម កុស្ស(COSS)

A4.4 ការកសាងសមត្ថភាពដើម្បីកែលម្អជំនាញរបស់អ្នកផ្តល់សេវា និងដោះស្រាយចន្លោះប្រព័ន្ធសេវាកម្ម

A4.5 ការរៀបចំចាប់ផ្ដើមប្រព័ន្ធ កុស្ស(COSS) និងការផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់អ្នកប្រើប្រាស់ កុស្ស(COSS) ដែលបានជ្រើសរើស (ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ភាគីទី៣)

**<u>ចក្ខុយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍អេកូទេសចរណ៍</u>**

លទ្ធផលដំបូងនៃការវាយតម្លៃ រេស្កូ(RESCO) គឺការកំណត់អត្តសញ្ញាណនៃចក្ខុវិស័យយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍខ្សែសង្វាក់តម្លៃអេកូទេសចរណ៍ដែលត្រូវសម្រេចនៅឆ្នាំ២០៣០ គឺមាន**ការកើនឡើងយ៉ាងហោចណាស់ ៣០% នៃចំនួនភ្ញៀវទេសចរណ៍ មកស្នាក់នៅកំសាន្តយ៉ាងតិច ២យប់ ជាមធ្យម។ ក្នុងនោះយើងក៏សំដៅយកភាពជំស្អាតស្រស់បំព្រងខុសប្លែកពីគេនៅក្នុងតំបន់ វិធានការការពារបរិស្ថាន និងវប្បធម៌អរិយធម៌ ដែលនេះអាចផ្ដល់ជាឱកាសការងារដល់ប្រជាពលរដ្ឋជាពិសេសអ្នកដែលខ្វះខាតបំផុត** ។ ជាការពិតណាស់ ភ្ញៀវទេសចរណ៍ដែលមកកាន់ខេត្តរតនគិរីនឹងរីករាយជាមួយនឹងតំបន់លំហែដែលមានទំហំផ្ទៃដីធំ តំបន់មានភាពទាក់ទាញដ៏ច្រើនដូចជា ទេសភាពធម្មជាតិ ភ្នំនិងព្រៃឈើឧទ្យានជាតិ ទឹកជ្រោះ បឹងធម្មជាតិ ទន្លេ ភ្នំភ្លើងបុរាណ កំសាន្តមើលសត្វស្លាប សកម្មភាពកីឡា និងកម្សាន្ត វប្បធម៌ ភូមិវប្បធម៌ជនជាតិដើមភាគតិច ជាមួយនឹងការតាំងពិព័ណ៌សិល្បៈ តន្ត្រីប្រពៃណីបុរាណ រួមទាំងរបាំ បទចម្រៀង និងឧបករណ៍តន្ត្រី រឿងព្រេងនិទាន និងទីកន្លែងបន់ស្រន់ ។

## *5.3.* គោលការណ៍យុទ្ធសាស្ត្រណែនាំ និងផែនការសកម្មភាពលម្អិត

*គោលការណ៍យុទ្ធសាស្ត្រណែនាំ ត្រូវបានពិពណ៌នាដោយយោងទៅលើ*

- ⊗ អាទិភាពដូចដែលបានកំណត់ខាងលើ
- ⊗ វិស័យយុទ្ធសាស្ត្រ៖ អភិបាលកិច្ច សេវាកម្ម និងការកសាងសមត្ថភាព
- ⊗ គោលដៅយុទ្ធសាស្ត្រ៖ ការបង្កើតវេទិកាសម្រាប់កិច្ចសន្ទនាសង្គម ដើម្បីពង្រឹងឱកាសការងារប្រចាំថ្ងៃសម្រាប់ប្រជាពលរដ្ឋក្នុងតំបន់ ការលើកកម្ពស់និរន្តរភាពសង្គម និងការលើកកម្ពស់និរន្តរភាពបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

## អាទិភាពទី ១

**A1.1: អភិបាលកិច្ច**

**A1.11***:* ការបង្កើតវេទិកាសម្រាប់កិច្ចសន្ទនាសង្គម ដើម្បីពង្រឹងឱកាសការងារប្រចាំថ្ងៃសម្រាប់ប្រជាជនគោលដៅ (តាមរយៈការរក្សាគុណប្រយោជន៍ការប្រកួតប្រជែង ការលើកតម្កើងភាពត្រឹមត្រូវ និងការការពារស្ថានភាពបរិស្ថានរបស់ខ្លួន) និងការរៀបចំផែនការសម្រាប់:

(a) លើកកម្ពស់ និងសម្របសម្រួលក្រុមបរិយាបន្នផ្នែកសង្គម-សេដ្ឋកិច្ច រួមបញ្ចូលទាំងស្ត្រី យុវជន បងប្អូនជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះ នៅក្នុងខ្សែសង្វាក់តម្លៃអេកូទេសចរណ៍ តាមរយៈលើកតម្កើងធនធានទេសចរណ៍

(b) ការបង្កើនចំនួន និងគុណភាពនៃកន្លែងដែលទាក់ទាញសម្រាប់ទេសចរណ៍ ទស្សនា រីករាយ និងលើកកម្ពស់បដិសណ្ឋារកិច្ច

(c) ការសហការជាមួយរដ្ឋាភិបាលជាតិជំរុញការពង្រឹងបទប្បញ្ញត្តិ និងផែនការគាំទ្រការការពារបរិស្ថាន និងផ្តល់ការលើកទឹកចិត្តចំពោះគំនិតផ្តួចផ្តើមអនុវត្តអាជីវកម្ម និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការសម្រាប់ភ្ញៀវទេសចរណ៍អាចទៅទស្សនាតំបន់វប្បធម៌អរិយធម៌បានយ៉ាងងាយស្រួល

(d) ការផ្សព្វផ្សាយ ការរៀបចំ និងការប្រមូលមូលនិធិសម្រាប់រៀបចំព្រឹត្តិការណ៍ កម្សាន្ត និងកម្មវិធីកម្សាន្តនានា

(e) ការពង្រឹងភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់ខេត្តរតនគិរីសម្រាប់ភ្ញៀវទេសចរណ៍៖ ព្រលានយន្តហោះ ផ្លូវថ្នល់ល្អ ហេដ្ឋារចនាសម្ព័ន្ធ និងសុខាភិបាល។

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាពរបស់ ខ្លេស៊ីដ្រា(CLESIDRA) ចំនុច WP2 (A.2.1)**

### A1.2 សេវាកម្ម

A1.21: ផ្តល់ការគាំទ្របច្ចេកទេសផ្នែក

(a) សិប្បកម្មដែលភាគច្រើនទាក់ទងនឹងវប្បធម៌ជនជាតិដើម និងអាជីវកម្មសាងសង់គ្រឿងសង្ហារឹមដោយប្រើប្រាស់សម្ភារៈនិងរចនាប័ទ្មក្នុងស្រុក

(b) បណ្តាញទំនាក់ទំនង ជាពិសេសអ្នកផ្តល់សេវាកម្ម

(c) ការសម្រេចបាននូវកិច្ចព្រមព្រៀងជាមួយនឹងប្រតិបត្តិករទេសចរណ៍ក្នុងស្រុក

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាពរបស់ ខ្លេស៊ីដ្រា(CLESIDRA) ចំនុច WP4 (A.4.4)**

A1.22: គាំទ្រដល់ការចាប់ផ្តើមអាជីវកម្ម ដូចជា៖

- គ្រឿងសង្ហារឹម និងសម្ភារៈសម្រាប់ផ្គត់ផ្គង់សណ្ឋាគារ និងភោជនីយដ្ឋាន
- សេវាកម្មថែទាំ និងជួសជុលសណ្ឋាគារ និងឧបករណ៍ផ្សេងៗ
- ការសាងសង់ និងថែទាំហេដ្ឋារចនាសម្ព័ន្ធ
- ការដឹកជញ្ជូន៖ មានតាក់ស៊ី ឡានក្រុងទេសចរណ៍ និងទូក
- សេវាកម្មថែទាំរថយន្តដឹកជញ្ជូន
- ភ្នាក់ងារទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍ និងមគ្គុទេសក៍

- ផលិតផលពីការកែច្នៃ៖ ជីវសាស្ត្រសម្រាប់ជីបង្កើនលក្ខណៈដី ផលិតផលជាច្រើនប្រភេទពីប្លាស្ទិក រួមទាំង) និងលោហៈ (សម្ភារៈ សិប្បកម្ម) សិប្បកម្មពីឈើក្បឿន (សិប្បកម្ម

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាពរបស់ ខ្លេស៊ីដ្រា(CLESIDRA) ចំនុច WP4 (A.4.5)**

**A1.3: ការកសាងសមត្ថភាព**

**A1.31**: ការកសាងសមត្ថភាពសម្រាប់ការរក្សាគុណប្រយោជន៍ប្រកួតប្រជែង ការលើកតម្កើងភាពត្រឹមត្រូវ និងការការពារស្ថានភាពបរិស្ថាន ដោយយោងជាពិសេសទៅលើការធ្វើឱ្យតួអង្គក្នុងស្រុក និងប្រជាជនយល់ដឹងអំពីសារៈសំខាន់នៃទេសចរណ៍ និងភ្ញៀវទេសចរណ៍សម្រាប់ការអភិវឌ្ឍន៍តំបន់ និងតួនាទីរបស់ពួកគេក្នុងការទាក់ទាញភ្ញៀវទេសចរណ៍។

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាពរបស់ ខ្លេស៊ីដ្រា(CLESIDRA) ចំនុច WP1 (A.1.2)**

**A1.32**: ការកសាងសមត្ថភាពសម្រាប់ជំនាញវិជ្ជាជីវៈ ដោយយោងជាពិសេសទៅលើ៖

- ប្រតិបត្តិករទេសចរណ៍
- មគ្គុទេសក៍ទេសចរណ៍
- បន្ទប់ អាហារ និងសេវាកម្ម៖ អ្នកជំនាញធ្វើភេសជ្ជៈ សេវាកម្មសម្អាត (សេវាកម្មក្រៅពីការសម្អាតផ្ទះ)
- ការរៀបចំកញ្ចប់ទេសចរណ៍ និងសេវាកម្មមគ្គុទេសក៍ទេសចរណ៍
- អនាម័យ និងសុខភាព (ការប្រមូល និងការបោះចោលសំរាម)

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាពរបស់ ខ្លេស៊ីដ្រា(CLESIDRA) ចំនុច WP1 (A.1.4)**

**A1.33**: ការកសាងសមត្ថភាពសម្រាប់ចីរភាពសង្គម តាមរយៈ

(a) កសាងសមត្ថភាពស្ត្រីដើម្បីសម្រួលដល់ការ

- ទទួលបានឪកាសការងារ ជាពិសេសនៅក្នុងវិស័យដឹកជញ្ជូន ការគ្រប់គ្រងគណនី និងសកម្មភាពជម្រុញវិស័យវប្បធម៌
- ទទួលបានឪកាសការងារក្នុងជួររដ្ឋបាលសាធារណៈ

(b) កសាងសមត្ថភាពចំពោះបុគ្គលដែលមានកាយសម្បទា និងផ្លូវចិត្តខុសពីគេ ដើម្បីទទួលបានឪកាសការងារដូចគ្នា

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាពរបស់ ខ្លេស៊ីដ្រា(CLESIDRA) ចំនុច WP1 (A.1.2)**

## អាទិភាពទី ២

**A2.1: អភិបាលកិច្ច**

**A2.11**: ការសម្រេចយុទ្ធសាស្រ្តទីផ្សារតំបន់ តាមរយៈផែនទីមូលដ្ឋានរួមមានកន្លែងទាក់ទាញផ្សេងៗនៅកម្រិតមូលដ្ឋាន សំណើរគម្រោងទេសចរណ៍ សៀវភៅការណែនាំជាភាសាផ្សេងៗ ការបង្កើតកម្មវិធីសម្រាប់សេវាកម្មព័ត៌មានទេសចរណ៍នៅកម្រិតតំបន់

**A2.12**: លើកកម្ពស់និរន្តរភាពសង្គម តាមរយៈការជំរុញរដ្ឋាភិបាលសម្រាប់៖

- សម្រួលដល់បុគ្គលដែលមានសមត្ថភាពរាងកាយ និងផ្លូវចិត្តខុសពីអ្នកដទៃ
- សម្រួលឲ្យស្ត្រីមានឱកាសការងារក្នុងតំណែងរដ្ឋបាលសាធារណៈ

**A2.13** លើកកម្ពស់និរន្តរភាពបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ តាមរយៈការជំរុញរដ្ឋាភិបាលជាតិ និងការពង្រឹងបទប្បញ្ញត្តិ និងផែនការគាំទ្រការការពារបរិស្ថាន និងផ្តល់លើកទឹកចិត្តដល់អ្នកដែលមានគំនិតផ្តួចផ្តើមអនុវត្តអាជីវកម្ម

**A2.2 សេវាកម្ម**

**A2.21**: ធ្វើឱ្យប្រសើរឡើងនូវសេវាកម្មសម្រាប់ការលើកកម្ពស់និរន្តរភាពបរិស្ថាន ដោយយោងជាពិសេសទៅលើការគាំទ្រក្រុមហ៊ុនដែលមានធ្វើការណែនាំ ឬការកែលម្អដំណោះស្រាយសម្រាប់និរន្តរភាពបរិស្ថាន៖ ប្រសិទ្ធភាពការប្រើប្រាស់ទឹក និងអគ្គិសនី និងការកាត់បន្ថយថ្លៃដើម ការបំភាយឧស្ម័ន CO2 ការគ្រប់គ្រងកាកសំណល់ ការបង្កើនអាយុកាលផលិតផល ការប្រើប្រាស់វត្ថុធាតុដើមកែច្នៃ ជាដើម

**A2.22: ពង្រឹងសេវាកម្មដូចខាងក្រោម៖**

- សេវាកម្មបច្ចេកទេស រដ្ឋបាល អង្គការស្ថាប័ន
- គណនីហិរញ្ញវត្ថុ
- ការចូលរួមក្នុងពិព័រណ៍អន្តរជាតិ
- សេវាកម្មសម្រាប់ភ្ញៀវទេសចរណ៍៖ ព័ត៌មានទូទៅ មគ្គុទេសក៍ ដឹកជញ្ជូន ការកក់ ជាដើម

**A2.23**: ស្វែងរកយន្តការដើម្បីសម្រួលដល់ការផ្តល់ហិរញ្ញវត្ថុដល់ខ្សែសង្វាក់តម្លៃតាមរយៈស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក

**A2.3: ការកសាងសមត្ថភាព**

**A2.31**: កសាងសមត្ថភាពរបស់អ្នកជំនួញសម្រាប់ការអនុវត្តដំណោះស្រាយសម្រាប់និរន្តរភាពបរិស្ថាន ទាក់ទងនឹង

- ប្រសិទ្ធភាពការប្រើប្រាស់ទឹក និងអគ្គិសនី និងការកាត់បន្ថយថ្លៃដើម
- ការបំភាយឧស្ម័ន (CO2)
- ការគ្រប់គ្រងកាកសំណល់

- ការបង្កើនអាយុកាលផលិតផល
- ការប្រើប្រាស់វត្ថុធាតុដើមកែច្នៃ
- ការប្រើប្រាស់ថាមពលឡើងវិញ

**A2.32**: កសាងសមត្ថភាពសម្រាប់ការបង្កើត និងការគ្រប់គ្រងយុទ្ធសាស្ត្រទីផ្សារក្នុងខេត្តរតនគិរី

**A2.33**: កសាងសមត្ថភាពរបស់តួអង្គក្នុងខ្សែសង្វាក់តម្លៃដើម្បីឱ្យពួកគេងាយស្រួលប្រើប្រាស់មូលនិធិជាតិ និងអន្តរជាតិ ក៏ដូចជាតាមរយៈការបង្ហាញពីការអនុវត្តល្អបំផុតដែលទាក់ទងនឹងបច្ចេកវិទ្យាថ្មីៗក្នុងវិស័យទេសចរណ៍

**A2.34**: កសាងសមត្ថភាពសម្រាប់ការលើកកម្ពស់និរន្តរភាពបរិស្ថាន តាមរយៈ៖

(a) ការកំណត់អត្តសញ្ញាណនៃការអនុវត្តល្អបំផុតនៃការការពារបរិស្ថាន និងការងារសម្រាប់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៅក្នុងបរិបទខេត្តរតនគិរី៖ ការកាត់បន្ថយការបំភាយឧស្ម័ន ($CO_2$) ការបំពុលដី និងទឹក ការអនុវត្តរង្វង់សេដ្ឋកិច្ចជាដើម។

(b) ការបង្កើតប្រព័ន្ធត្រួតពិនិត្យលើប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទឹកក្នុងរយៈពេលវែង។

(c) ការអនុវត្តគំនិតផ្តួចផ្តើមសម្រាប់ការលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនអំពីហានិភ័យនៃការបំពុលដី និងខ្យល់ និងការប្រែប្រួលអាកាសធាតុ និងវិធានការការពារ។

(d) កសាងសមត្ថភាពសម្រាប់ការអន្តរាគមន៍របស់ VOGE

## អាទិភាពទី ៣

### A3.1 **អភិបាលកិច្ច**

*A.3.11: ប្រើប្រាស់ ផ្លាសិដ(PLASED) សម្រាប់៖*

(a) បង្កើតជាស្ថាប័នឯកជនសាធារណៈដែលអាចផ្គត់ផ្គង់គ្រឿងសង្ហារឹម

(b) បង្កើតបានមណ្ឌលសម្រាប់កក់(*សំបុត្រ ឬសេវាកម្ម*) និងការគ្រប់គ្រង

(c) ការលើកកម្ពស់ការការពារបរិស្ថាន ដោយយោងជាពិសេសទៅលើ

- ការបង្កើតប្រព័ន្ធត្រួតពិនិត្យលើប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទឹកក្នុងរយៈពេលវែង
- ការរៀបចំក្រុមស្ម័គ្រចិត្តសម្រាប់បរិស្ថានខេត្ត )VOGE)
- ការសម្រេចបាននូវកិច្ចព្រមព្រៀងជាមួយស្ថាប័នស្រាវជ្រាវសម្រាប់ការស្វែងរកដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតសម្រាប់រង្វង់សេដ្ឋកិច្ច ៖ ការបង្កើតឡើងវិញការកែច្នៃឡើងវិញ-ការប្រើប្រាស់ឡើងវិញ-
- ការជំរុញរដ្ឋាភិបាលដើម្បីណែនាំនូវយន្តការដើម្បីសម្រួលដល់ការធានារ៉ាប់រងប្រឆាំងនឹងហានិភ័យនៃការប្រែប្រួលអាកាសធាតុ

### A3.2: **សេវាកម្ម**

A3.21: គាំទ្រដល់ប្រតិបត្តិករទេសចរណ៍សម្រាប់ការសម្រួលដល់ការណែនាំនូវបច្ចេកវិទ្យាថ្មីៗ

A3.22: ពង្រឹងសេវាកម្មសម្រាប់ការការពារបរិស្ថាន ដូចជា៖

- ការសម្រេចបាននូវការទស្សន៍ទាយ និងការការពារហានិភ័យនៃប្រភពដើមរបស់សត្វ និងប្រភពដើមធម្មជាតិ
- ការវាស់វែង និងតាមដានការបំពុលបរិស្ថាន ព័ត៌មានអំពីបរិស្ថាន
- ការគាំទ្រ ដល់អាជីវកម្មដែលមានលក្ខណៈបរិស្ថានសេរី និងការសម្រួលដល់ការគាំទ្រហិរញ្ញវត្ថុដល់អាជីវកម្មនោះផងដែរ
- ការគាំទ្រដល់ការបង្កើតក្រុមហ៊ុនដែលប្រមូលសម្រាមដោយមានការទុកដាក់បានត្រឹមត្រូវទាំងការបែងចែកសម្រាមតាមប្រភេទ ផ្ទុក និងលក់។

**A3.3 ការកសាងសមត្ថភាព**

**A3.31**: ការកសាងសមត្ថភាពសម្រាប់ការគ្រប់គ្រងបដិសណ្ឋារកិច្ចផ្សេងៗ និងសកម្មភាពទាំងឡាយណាដែលទាក់ទងនឹងទេសចរណ៍

A3.32: ការកសាងសមត្ថភាពសម្រាប់សហគមន៍ក្នុងតំបន់។

- ការគ្រប់គ្រងកិច្ចសន្ទនាសង្គម និងការសម្រេចចិត្តរួមគ្នា
- ទីផ្សារ និងការផ្តោតលើអតិថិជន
- ភាពជាអ្នកដឹកនាំ

## សង្ខេបគោលការណ៍ណែនាំយុទ្ធសាស្ត្រសំខាន់ៗ

ប្រអប់ខាងក្រោមបង្ហាញពីក្តីសង្ខេបនៃគោលការណ៍ណែនាំយុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃអេកូទេសចរណ៍ សម្រាប់អាទិភាពលេខ ១ និង ២

ប្រអប់ទី ១ សង្ខេបនៃគោលការណ៍ណែនាំយុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃអេកូទេសចរណ៍សម្រាប់អាទិភាពលេខ ១ (ប្រភព៖ ILS LEDA)

| អាទិភាព 1 | ការបរិយាយ |
|---|---|
| **អភិបាលកិច្ច** | បង្កើតគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ ដោយផ្អែកលើតាមការចូលរួមរបស់ក្រុមចម្បង (focus group) និងក្រុមរងរបស់ ផ្លាសិដ(PLASED) សម្រាប់<br>• ការសម្រួលដល់បរិយាបន្នសង្គមសេដ្ឋកិច្ច-<br>• ការបង្កើនចំនួន និងគុណភាពនៃកន្លែងទេសចរណ៍ដែលទាក់ទាញ |

| | |
|---|---|
| | • ការលើកកម្ពស់បដិសណ្ឋារកិច្ច<br>• ការជំរុញរដ្ឋាភិបាលជាតិសម្រាប់ការពង្រឹងបទប្បញ្ញត្តិ និងផែនការគាំទ្រខ្សែសង្វាក់តម្លៃ<br>• ការប្រមូលមូលនិធិ<br>• ការពង្រឹងភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់រតនគិរី |
| **ការកសាងសមត្ថភាព** | ធ្វើឱ្យតួអង្គក្នុងតំបន់ និងប្រជាជនយល់ដឹងអំពីសារៈសំខាន់នៃទេសចរណ៍ និងភ្ញៀវទេសចរណ៍ |
| | ជំនាញវិជ្ជាជីវៈ ដូចជា ប្រតិបត្តិករទេសចរណ៍ មគ្គុទេសក៍ទេសចរណ៍ សេវាកម្មសណ្ឋាគារ និងភោជនីយដ្ឋាន |
| | ការកសាងសមត្ថភាពសម្រាប់ស្ត្រីដើម្បីមានឱកាសការងារក្នុងវិស័យរដ្ឋបាលសាធារណៈ |
| | ការកសាងសមត្ថភាពដល់បុគ្គលដែលមានសមត្ថភាពរាងកាយ និងផ្លូវចិត្តខុសពីអ្នកដទៃ ក៏អាចទទួលបានឱកាសការងារដូចអ្នកដទៃទូទៅដែរ |
| **សេវាកម្ម** | ការបង្កើតប្រព័ន្ធសេវាកម្មដ៏ទូលំទូលាយ ដោយយោងជាពិសេសទៅលើ៖ ការគាំទ្របច្ចេកទេសដល់វិស័យសិប្បកម្ម បណ្តាញទំនាក់ទំនង ការសម្រេចបាននូវកិច្ចព្រមព្រៀងជាមួយនឹងប្រតិបត្តិករទេសចរណ៍ជាតិជាច្រើន។ |
| | គាំទ្រដល់ការចាប់ផ្តើមអាជីវកម្មដំបូង។ |

ប្រអប់ទី ២ សង្ខេបនៃគោលការណ៍ណែនាំយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃអេកូទេសចរណ៍សម្រាប់អាទិភាពលេខ ២ (ប្រភព៖ ILS LEDA)

| អទិភាព 2 | ការបរិយាយ |
|---|---|
| **អភិបាល** | ការសម្រេចយុទ្ធសាស្ត្រទីផ្សារតំបន់ |
| | ការលើកកម្ពស់និរន្តរភាពសង្គម |
| | ការលើកកម្ពស់និរន្តរភាពបរិស្ថាន |
| **ការកសាងសមត្ថភាព** | ការកសាងសមត្ថភាពរបស់អ្នកជំនួញសម្រាប់ការអនុវត្តដំណោះស្រាយសម្រាប់និរន្តភាពបរិស្ថាន |
| | ការកសាងសមត្ថភាពសម្រាប់ការបង្កើត និងការគ្រប់គ្រងយុទ្ធសាស្ត្រទីផ្សារក្នុងខេត្តរតនគិរី |
| | ការកសាងសមត្ថភាពរបស់តួអង្គខ្សែសង្វាក់តម្លៃដើម្បីឱ្យពួកគេងាយស្រួលយល់ដឹង និងប្រើប្រាស់មូលនិធិជាតិ និងអន្តរជាតិ |

| | |
|---|---|
| | ការកសាងសមត្ថភាពសម្រាប់ការលើកកម្ពស់និរន្តភាពបរិស្ថាន |
| **សេវាកម្ម** | ការលើកកម្ពស់សេវាកម្មដែលផ្តោតលើនិរន្តភាពនៃបរិស្ថាន |
| | ពង្រឹងសេវាកម្ម ដូចជា សេវាកម្មបច្ចេកទេស រដ្ឋបាល អង្គការស្ថាប័ន គណនីហិរញ្ញវត្ថុ ការចូលរួមក្នុងពិព័រណ៍អន្តរជាតិ សេវាកម្មសម្រាប់ភ្ញៀវទេសចរណ៍៖ ព័ត៌មាន មគ្គុទេសក៍ ដឹកជញ្ជូន ការកក់សេវា ជាដើម។ |
| | ស្វែងរកយន្តការដើម្បីសម្រួលដល់ការផ្តល់ហិរញ្ញវត្ថុដល់ខ្សែសង្វាក់តម្លៃតាមរយៈស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក |

Civil society Links and Empowerment for Socially Inclusive Development in Ratanakiri

ឯកសារនេះត្រូវបានរៀបចំឡើងក្នុងក្របខ័ណ្ឌនៃគម្រោង CLESIDRA ដែលទទួលបានជំនួយហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។ ទស្សនៈរបស់អ្នកនិពន្ធដែលបានបង្ហាញនៅទីនេះមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបទេ ហើយក៏មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់តំណាងរបស់សហភាពអឺរ៉ុបដែរ។ សហភាពអឺរ៉ុបមិនទទួលខុសត្រូវចំពោះមតិយោបល់របស់អ្នកនិពន្ធទេ។

This project is funded by the European Union